សាលាអន្តរជាតិ
បាមប៊ូចាយ៉ា

BAMBUJAYA
INTERNATIONAL SCHOOL

# គោលដៅសិក្សាសម្រាប់មុខវិជ្ជាភាសាខ្មែរ ថ្នាក់ទី១

បន្ទាប់ពីបញ្ចប់កម្មវិធីសិក្សាថ្នាក់ទី១ សិស្សានុសិស្សនឹងអាចៈ

## មូលដ្ឋានគ្រឹះនៃការយល់ដឹងពីភាសាខ្មែរ

- រៀបស្រៈតាមលំដាប់លំដោយ
- យល់ពីភាពខុសគ្នាក្នុងការប្រើប្រាស់ព្យញ្ជនៈនិងស្រៈ និងចាប់ផ្តើមការប្រកប
- យល់ពីការផ្លាស់ប្តូរសម្លេងរបស់ព្យញ្ជនៈមួយចំនួននៅពេលប្រើប្រាស់ ៊ និង ៉

## ការស្តាប់

- សម្គាល់សម្លេងរបស់ព្យញ្ជនៈ ៣៣តួ និងស្រៈនិស្ស័យទាំង ២៣តួ
- សម្គាល់ភាពខុសគ្នារវាងសម្លេងរបស់ព្យញ្ជនៈទាំងពីរក្រុម (អ និង អ៊)
- សម្គាល់សម្លេងក្នុងការប្រកបពាក្យងាយៗដែលមានព្យញ្ជនៈជាមួយនឹងស្រៈ និងព្យញ្ជនៈជាមួយនឹងព្យញ្ជនៈ
- ស្តាប់រឿងដោយយកចិត្តទុកដាក់ និងអាចប្រាប់ពីគំនិតសំខាន់ក្នុងរឿង
- បង្ហាញការគោរពទៅអ្នកដទៃនៅពេលគេកំពុងនិយាយ និងរង់ចាំដល់វេនរបស់ខ្លួនដើម្បីនិយាយ
- ធ្វើតាមការណែនាំងាយៗ
- កត់សម្គាល់សម្លេងផ្សេងៗគ្នាក្នុងការប្រកប

## ការនិយាយ

- បញ្ចេញសម្លេងរបស់ព្យញ្ជនៈនិងស្រៈនិស្ស័យបានត្រឹមត្រូវ
- ប្រកបព្យញ្ជនៈនិងស្រៈ
- និយាយល្បះដែលមានន័យពេញលេញត្រឹមត្រូវ
- ច្រៀងចម្រៀងងាយៗ

## ការសរសេរ

- សរសេរព្យញ្ជនៈនិងស្រៈនិស្ស័យបានត្រឹមត្រូវ
- សរសេរតាមអានពាក្យងាយៗបានត្រឹមត្រូវ

- ចម្លងអត្ថបទងាយៗពីក្ដារខៀន ឬសៀវភៅ

**ការអាន**

- សម្គាល់ព្យញ្ជនៈនិងស្រៈនិស្ស័យ
- អានពាក្យងាយៗដែលប្រកបដោយព្យញ្ជនៈជាមួយស្រៈ និងព្យញ្ជនៈ
- អានអត្ថបទខ្លីងាយៗ
- ចាប់ផ្ដើមកត់សម្គាល់ការប្រកប

## គោលដៅសិក្សាសម្រាប់មុខវិជ្ជាភាសាអង់គ្លេស ថ្នាក់ទី១

បន្ទាប់ពីបញ្ចប់កម្មវិធីសិក្សាថ្នាក់ទី១ សិស្សានុសិស្សនឹងអាចៈ

**ការស្ដាប់**

- ស្គាល់សម្លេងផ្សេងៗនៃព្យញ្ជនៈនិងស្រៈ
- ស្ដាប់រឿងដោយយកចិត្តទុកដាក់និងដឹងសាច់រឿងខ្លះៗ
- បង្ហាញនូវការគោរពនិងរង់ចាំវេនរបស់ខ្លួន កំឡុងពេលដែលអ្នកដទៃកំពុងនិយាយ
- ធ្វើតាមការណែនាំពីពីរទៅបីចំណុច

**ការនិយាយ**

- ប្រើការបញ្ចេញសម្លេងឲ្យបានត្រឹមត្រូវ
- និយាយបានច្បាស់លាស់និងអាចស្ដាប់បាន
- បង្ហាញពីគំនិតនៅក្នុងល្បះងាយៗ
- ចូលរួមក្នុងការពិភាក្សាអំពីប្រធានបទទូទៅផ្សេងៗ
- អាចប្រើពាក្យបានទូលាយដើម្បីបង្ហាញគំនិតនិងអារម្មណ៍
- សួរនិងឆ្លើយសំណួរជាក់លាក់
- សូត្រកំណាព្យខ្លីៗ ពាក្យចួន ចម្រៀង និងឃ្លាចួនខ្លីៗ

**ការសរសេរ**

- ចេះសរសេរអក្សរតូចនិងអក្សរធំបានត្រឹមត្រូវ
- ចម្លងអត្ថបទពីក្ដារខៀនជាមួយនឹងការប្រកបត្រឹមត្រូវ
- ស្គាល់ពាក្យងាយៗដែលជួបញឹកញាប់
- សរសេរពីឆ្វេងទៅស្ដាំឲ្យបានស្មើរគ្នា
- ប្រើប្រាស់គម្លាតបានត្រឹមត្រូវរវាងពាក្យនីមួយៗ

**ការអាន**

- អានអត្ថបទដែលបានចម្លងរួច
- ស្គាល់ពាក្យដែលជួបញឹកញាប់
- ប្រកបសម្លេងព្យញ្ជនៈ
- ចេះកំណត់សម្លេងដំបូង កណ្តាល និងចុងក្រោយ
- យល់ពីអត្ថបទដែលអានដោយមនុស្សធំ

## គោលដៅសិក្សាសម្រាប់មុខវិជ្ជាគណិតវិទ្យា ថ្នាក់ទី១

បន្ទាប់ពីបញ្ចប់កម្មវិធីសិក្សាថ្នាក់ទី១ សិស្សានុសិស្សនឹងអាចៈ

**យល់ដឹងអំពីលេខ**

- អាននិងសរសេរលេខខ្មែរចាប់ពីលេខ១ដល់លេខ១០០
- ប្រៀបធៀបទំហំវត្ថុ
- យល់ពីប្រមាណវិធីទាំងបួនគឺប្រមាណវិធីបូក ប្រមាណវិធីដក ប្រមាណវិធីគុណ និងប្រមាណវិធីចែក
- សម្គាល់ទំនាក់ទំនងរវាងប្រមាណវិធីបូកនិងប្រមាណវិធីដក
- ដឹងថាប្រមាណវិធីគុណគឺកើតចេញពីផលបូកលេខដូចគ្នានិងតគ្នា
- រាប់លេខទៅមុខនិងថយក្រោយដល់១០០
- រៀបលេខតាមលំដាប់លំដោយដល់១០០
- ប្រៀបធៀបលេខដើម្បីបង្ហាញថាមួយណាធំជាងនិងតូចជាងរហូតដល់ ១០០
- ប្រើប្រាស់របស់ផ្សេងៗដើម្បីធ្វើប្រមាណវិធីបូកក្នុងវិធីផ្សេងៗគ្នា
- រាប់លេខចន្លោះ ២ ៣ ៥ និង១០

**ការគណនា**

- បូកនិងដកលេខ១ខ្ទង់
- បូកលេខ១ខ្ទង់និងលេខ២ខ្ទង់ដោយគ្មានត្រាទុក
- ដកលេខ២ខ្ទង់និង១ខ្ទង់ដោយគ្មានការខ្ចី
- បូកនិងដកលេខដល់ ១២
- ដោះស្រាយលំហាត់ងាយៗដោយប្រើប្រមាណវិធីទាំងបួន បូក ដក គុណ និងចែក

**ធរណីមាត្រ**

- ស្គាល់ គូរ និងហៅឈ្មោះរិមាត្រក្នុងធរណីមាត្រដូចជាការេ រង្វង់ ត្រីកោណ និងចតុកោណ
- ទះដៃនិងបោះជំហានដើម្បីដឹងពីលំនាំនៃលេខ
- ស្គាល់លំដាប់លេខ

- កំណត់អត្តសញ្ញាណទីតាំងដូចជាខាងស្តាំ ខាងឆ្វេង  ខាងមុខ ខាងក្រោយ ខាងលើ  និងខាងក្រោម

## គោលដៅសិក្សាសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រសង្គម ថ្នាក់ទី១

មុខវិជ្ជាវិទ្យាសាស្ត្រសង្គមត្រូវបានបញ្ចូលនៅក្នុងមេរៀនផ្សេងៗទាំងក្នុងថ្នាក់ខ្មែរនិងថ្នាក់អង់គ្លេស ដែលត្រូវបានបង្រៀន ជាមេរៀនជាក់លាក់ឬត្រូវបានបញ្ចូលទៅក្នុងថ្នាក់មួយចំនួនមានដូចជា ថ្នាក់ចម្អិនម្ហូប ថ្នាក់ដាំដំណាំ ថ្នាក់សម្តែង និងថ្នាក់ធ្វើ ចលនា។ ដោយទាំងនេះមាន រួមបញ្ចូលនូវបំណិនជីវិតដែលអាចអនុវត្តជាក់ស្តែង ដែលគួរអោយចាប់អារម្មណ៍ និងអាច ជួយក្មេងៗក្នុងការពង្រឹងនូវជំនាញដែលពួកគេនឹងត្រូវប្រើប្រាស់សម្រាប់ឆ្នាំសិក្សាខាងមុខ។ សម្រាប់ថ្នាក់ដំបូង មុខវិជ្ជា វិទ្យាសាស្ត្រសង្គមត្រូវបានផ្តោតលើការប្រាស្រ័យទាក់ទងគ្នាជាមួយនឹងពិភពលោក និងមនុស្សនៅជុំវិញដើម្បីអភិវឌ្ឍការ យល់ពីសង្គមនិងការមានឥរិយាបទល្អនៅក្នុងសង្គម។ នៅពេលដែលមុខវិជ្ជានេះត្រូវបានសិក្សាឲ្យបានកាន់តែស៊ីជម្រៅនៅ ថ្នាក់ខាងមុខទៀត ក្មេងៗបានយល់ដឹងនិងមានការផ្សារភ្ជាប់ជាមួយនឹងពិភពលោកនិងកន្លែងដែលពួកគេរស់នៅរួចជាស្រេច ។

បន្ទាប់ពីបញ្ចប់កម្មវិធីសិក្សាថ្នាក់ទី១ សិស្សានុសិស្សនឹងអាចៈ

**វិទ្យាសាស្ត្រសង្គម**
- និយាយនិងធ្វើការណែនាំពីខ្លួនឯង សមាជិកគ្រួសារ និងសាច់ញាតិផ្សេងទៀត
- បង្ហាញការគោរពចំពោះអ្នកដទៃ បរិស្ថានធម្មជាតិនិងសម្ភារសាលា និងដឹងពីទីកន្លែងរបស់ពួកគេ
- រៀនពីកំហុសដែលបានធ្វើ និងពីឥរិយាបទល្អៗ
- បង្ហាញពីមូលដ្ឋានគ្រឹះនៅក្នុងការថែទាំដំណាំ
- ស្គាល់សត្វព្រៃនិងសត្វស្រុកព្រមទាំងអាកប្បកិរិយារបស់ពួកវា
- មានការយល់អំពីលក្ខណៈផ្សេងៗគ្នារបស់វត្ថុមានដូចជា ក្តៅ ត្រជាក់ រឹង ទន់ ស្រួច និងទាលជាដើម
- អនុវត្តទម្លាប់ក្នុងការធ្វើអនាម័យល្អនិងការរក្សាសុវត្ថិភាព ជាពិសេសនៅក្នុងថ្នាក់ចម្អិនម្ហូបអាហារ
- ពណ៌នាពីពេលថ្ងៃនិងពេលយប់ និងយល់ពីភាពខុសគ្នារបស់វា
- ផ្តល់ឧទាហរណ៍ពីអាកាសធាតុនិងភាពខុសគ្នានៃរដូវនីមួយៗ
- ពណ៌នាអំពីអ្វីដែលពួកគេសង្កេតនៅក្នុងធម្មជាតិទាំងរុក្ខជាតិនិងសត្វ
- បំពេញការងារហត្ថកម្ម ជាពិសេសទាក់ទងនឹងការប្រារព្ធពិធីបុណ្យផ្សេងៗ